00896194

E275

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសជ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៩ ខែមីនា ឆ្នាំ ២០១៣

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
29 / 03 / 2013
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**: (ឧបសម្ព័ន្ធសាធារណៈ និងសម្ងាត់)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ / Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសុំដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តារ

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ូច ស្រីផាត់

លោកស្រី សុគន្ធ មោនីកា

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទៅលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយបានប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីលើសំណុំរឿង ០០២ និងបានកត់សម្គាល់ថាភាគីបានទទួលរងនូវព្យសនកម្មជាច្រើន[1]។

២. នៅថ្ងៃទី ១៨ ថ្ងៃទី ២០ និងថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការលើផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល[2]។ ក្នុងសវនាការនោះមេធាវីការពារក្តីលោក ខៀវ សំផន បានប្រកាសថានឹងដាក់សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[3]។

៣. ជាក់ស្តែង ស្ថានភាពបច្ចុប្បន្នស្តែងឡើងឱ្យឃើញយ៉ាងច្បាស់ថា ការជំនុំជម្រះក្តីលោក ខៀវ សំផន មិនងាយនឹងបញ្ចប់នោះទេ បើទោះបីជានឹងបញ្ចប់នៅថ្ងៃណាមួយក៏ដោយ។ លទ្ធភាពនៃការចេញសាលក្រមទៀតសោតក៏រឹតតែនៅឆ្ងាយសន្លឹម។

៤. ក្រោយពីស៊ើបសួរអស់រយៈពេលបីឆ្នាំ និងជំនុំជម្រះក្តីអស់រយៈពេលជាងពីរឆ្នាំមក ផលវិបាកកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធីដែលត្រូវបានធ្វើមោឃភាព រួមនឹងផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីថ្មីជាយថាហេតុ ស្របតាមការបញ្ញត្តិរបស់អង្គជំនុំជម្រះតុលាការកំពូល គឺជាការប៉ះពាល់ទៅដល់ភាពឆាប់រហ័សនៃការជំនុំជម្រះក្តីនេះ ដែលភាពយុត្តិធម៌ត្រូវបានចោទជាបញ្ហាយ៉ាងធ្ងន់ធ្ងរដោយអង្គជំនុំជម្រះតុលាការកំពូល។

---

[1] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី")។ *[ជូនដំណឹងជាភាសាបារាំង នៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣]*។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/171.1, ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/172.1, ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/173.1។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/172.1 ទំព័រ ៥៤។

៥. តើលោក ខៀវ សំផន នឹងត្រូវជំនុំជម្រះលើបទចោទទាំងមូល ដូចមានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ យ៉ាងដូចម្តេច និងនៅពេលណា? រហូតមកទល់នឹងថ្ងៃនេះ សំណួរនេះហាក់ដូចជាមិនទាន់មានចម្លើយនៅឡើយទេ។

៦. ក្រោយពីបានបង្គាប់ឱ្យឃុំខ្លួនលោក ខៀវ សំផន បណ្តោះអាសន្នអស់រយៈពេលជាងប្រាំឆ្នាំមក កាលពីពេលថ្មីៗកន្លងទៅនេះ លោក Marcel LEMONDE បានប្រកាសនៅក្នុងកិច្ចសម្ភាសន៍មួយប្រាប់សារព័ត៌មានថា ការជំនុំជម្រះក្តីលើសំណុំរឿង ០០២ ឈានទៅមុខ *"យ៉ាងរឹករវ និងកាន់តែខុសពីការរំពឹងចង់បាន៖ យឺតយ៉ាវ វិវាទខាងនីតិវិធីមិនចេះចប់មិនចេះហើយ សុខភាពមិនរឹងប៉ឹងរបស់ជនជាប់ចោទ ហិរញ្ញប្បទានមិនប្រាកដប្រជា។ មូលហេតុនៃការព្រួយបារម្ភកាន់តែពូនជ្រំផ្តុំច្រើនឡើងៗ...។ គ្មាននរណាម្នាក់អាចនិយាយបានថា តើការជំនុំជម្រះក្តីនោះបញ្ចប់ដោយរបៀបណានោះទេ ប៉ុន្តែ សង្ឃឹមតិចណាស់ថានឹងបញ្ចប់ទៅយ៉ាងល្អប្រសើរនោះ។ ទោះជាមានសាលក្រមនៅថ្ងៃណាមួយ ក៏គេមិនដឹងថា តើសាលក្រមនឹងត្រូវចេញនៅថ្ងៃណានោះដែរ"*[4]។

៧. ទោះបីជាត្រូវឃុំខ្លួន "បណ្តោះអាសន្ន" អស់រយៈពេលប្រាំឆ្នាំបួនខែមកហើយ ក៏លោក ខៀវ សំផន នៅតែត្រូវបានសន្មតថាគ្មានទោស។ សព្វថ្ងៃនេះ គាត់មានអាយុជិត ៨២ ឆ្នាំហើយ។

៨. មេធាវីការពារក្តីលោក ខៀវ សំផន ស្នើឱ្យអង្គជំនុំជម្រះកត់សម្គាល់រួមជាមួយយើងខ្ញុំថា ល័ក្ខខ័ណ្ឌបញ្ជាក់អំពីការបន្តឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានបំពេញទៀតឡើយ។ បរិបទបច្ចុប្បន្នតម្រូវឱ្យដាក់ លោក ខៀវ សំផន ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយសារតែភាពមិនប្រាកដប្រជានៃកិច្ចដំណើរការនីតិវិធីនេះ។

៩. យោងទៅលើសារៈសំខាន់នៃបញ្ហាដែលដាក់ជូនអង្គជំនុំជម្រះនៅពេលនេះ និងបន្ទុកបង្ហាញរបស់មេធាវីការពារក្តី[5] យើងខ្ញុំស្នើសុំឱ្យបើកសវនាការជាសាធារណៈ និងចំពោះមុខ ដើម្បីឱ្យយើងខ្ញុំ

---

[4] បទសម្ភាសន៍ជាមួយ Marcel Lemonde ជាអ្នកនិពន្ធសៀវភៅ un juge face aux Khmers Rouges ប្រមូលចងក្រងដោយ Ghislain Poissonnier (http://www.lepetitjournal.com/bangkok) ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[5] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ អង្គជំនុំជម្រះតុលាការកំពូល

អាចបង្ហាញទឡ្ហីករណ៍ ដែលមកទល់នឹងថ្ងៃនេះ យើងខ្ញុំបានត្រឹមតែធ្វើឡើងជាលាយលក្ខណ៍អក្សរទៅតាមចំនួនទំព័រកំណត់ដោយអង្គជំនុំជម្រះ[6]។

## I- ការបន្តឃុំខ្លួនមិនមានមូលដ្ឋានទៀតទេ

១០. នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យបន្តឃុំខ្លួនលោក ខៀវ សំផន ដោយយល់ឃើញថា *"មានមូលហេតុអាចជឿជាក់បានថា ជនជាប់ចោទបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់"*[7]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា *"ប្រសិនបើតុលាការរកឃើញថា ខៀវ សំផន មានពិរុទ្ធភាពនោះ ការប្រឈមមុខនឹងការផ្តន្ទាទោសធ្ងន់ធ្ងរអាចជំរុញឱ្យគាត់រត់គេចខ្លួន ក្រោយពីដោះលែងឱ្យនៅក្រៅឃុំ។ ការបន្តឃុំខ្លួនជាល័ក្ខខ័ណ្ឌចាំបាច់ ដើម្បីធានាថាគាត់នឹងមានវត្តមាននៅគ្រប់ដំណាក់កាលនៃសវនាការ"*[8]។

១១. នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហាខ្វះសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបញ្ជាក់ហេតុផលបន្តឃុំខ្លួន ផ្អែកលើហានិភ័យថាជនជាប់ចោទអាចនឹងមិនមានវត្តមាន ក្នុងពេលជំនុំជម្រះក្តី[9]។

១២. នៅឆ្នាំ២០១១ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការជំនុំជម្រះក្តីលើសំណុំរឿង ០០២ គឺជា *"កិច្ចការដ៏ធំធេងទាំងខាងផ្នែករៀបចំ និងភ័ស្តុភារ"*។ អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា *"ការខកខានរបស់ជនជាប់ចោទណាមួយមិនបង្ហាញខ្លួនសូម្បីតែម្តង អាចនឹងប៉ះពាល់ដល់លទ្ធភាពនៃការចេញសាលក្រមក្នុងរយៈពេលសមស្រប"*។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងអំពី

---

ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E50/3/1/4 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន") កថាខណ្ឌ ៤៨ និងកថាខណ្ឌ ៥៧។

[6] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក មាត្រា ៥(១)

[7] សេចក្តីសម្រេចលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E50 ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១") កថាខណ្ឌ ៣៨។

[8] ដូចយោងខាងលើ កថាខណ្ឌ ៤០។

[9] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥២ កថាខណ្ឌ ៥៤ និងផ្នែកសម្រេចសេចក្តី។

ហានិភ័យថា ខៀវ សំផន អាចលាក់ខ្លួន ព្រងើយកន្តើយចំពោះដីកាកោះ ឬមានបញ្ហារាំងបណ្ដោះអាសន្ន។ លើសពីនេះ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងអំពីហានិភ័យនៃការរំខានដល់សណ្ដាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សុវត្ថិភាពរបស់ជនជាប់ចោទ និងកង្វះការថែទាំវេជ្ជសាស្ត្រសមស្រប នៅពេលគាត់ត្រូវការ[10]។

## ក. ហានិភ័យនៃការប៉ះពាល់ដល់លទ្ធភាពចេញសាលក្រមក្នុងរយៈពេលសមស្រប

១៣. ជិតពីរឆ្នាំ ក្រោយពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ខែ មិថុនា ឆ្នាំ ២០១១ ហានិភ័យនៃការប៉ះពាល់ដល់លទ្ធភាពចេញសាលក្រមក្នុងរយៈពេលសមស្រប គឺជាការពិត។ ប៉ុន្តែ លោក ខៀវ សំផន មិនត្រឹមតែមិនមែនជាដើមហេតុនោះទេ គឺគាត់ជាអ្នកទទួលរងនូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

### ១. ការប៉ះពាល់ជាក់ស្ដែងទៅលើលទ្ធភាពនៃការចេញសាលក្រមក្នុងរយៈពេលសមស្រប និងការរំលោភសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន

១៤. **ភាពឆាប់រហ័សនៃការជំនុំជម្រះក្ដី**ត្រូវបានរាំងយ៉ាងខ្លាំងក្លា។ ភាពយឺតយ៉ាវជាច្រើនបានកើតឡើង ហើយនៅតែបន្តកើតឡើងទៀត គឺមិនមែនព្រោះតែលោក ខៀវ សំផន អវត្តមានជាច្រើនដង ដោយសារបញ្ហាសុខភាពនោះទេ[11]។

១៥. ជាក់ស្ដែង ភាពយឺតយ៉ាវជាច្រើនបានកើតឡើងដោយសារតែជម្រើស និងការភាន់ច្រឡំរបស់ភាគីមួយចំនួន និងអង្គជំនុំជម្រះសាលាដំបូង។ ឧទាហរណ៍ សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី បានជ្រើសរើសយកការបង្ហាញឯកសាររាប់ពាន់ ហើយអង្គជំនុំជម្រះបានជ្រើសរើសមិនឱ្យពួកគេពិនិត្យមើលបញ្ជីឯកសាររបស់ខ្លួនឡើងវិញ កំណត់កម្រិតនៃភាពអាចទទួលយកបានយ៉ាង

[10] ដូចយោងខាងលើ កថាខណ្ឌ ៥៤។

[11] លោក ខៀវ សំផន *"ខកខានមិនបានចូលរួមសវនាការ"* តែម្ដងគត់ ដោយសារតែគាត់មានជំងឺរលាកទងសួតត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ រយៈពេលពីរបីថ្ងៃ ក្នុងខែ មករា កន្លងទៅនេះ។

ទូលំទូលាយបំផុត និងធ្វើសវនាការ ដោយគ្មានការពិភាក្សាដេញដោលតទល់ ដើម្បីឲ្យអង្គជំនុំជម្រះជ្រើសសម្រាំងពីគំនរឯកសារ[12]។

១៦. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានជ្រើសរើសការបំបែកបទចោទ និងបំបែកការជំនុំជម្រះក្តីជាច្រើនវគ្គ[13]។ ជាងមួយឆ្នាំក្រោយមក សហព្រះរាជអាជ្ញាបានជ្រើសរើសយកការប្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីនេះ[14]។ អង្គជំនុំជម្រះតុលាការកំពូលបានស្រង់នូវកំហុសជាច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង ហើយបានធ្វើមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី ដែលជាមូលដ្ឋាននៃការជំនុំជម្រះក្តីវគ្គមួយ[15]។ ក្នុងបរិបទខុសពីធម្មតានេះ អង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាលើបែបបទនៃការបំបែកកិច្ចដំណើរការនីតិវិធីថ្មី[16]។

១៧. ក្រៅពីលទ្ធភាពនៃការចេញសាលក្រមក្នុងរយៈពេលសមស្រប **គឺលទ្ធភាពនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌** ដែលទទួលរងនូវការប៉ះពាល់។ ជាក់ស្តែង ខណៈពេលជ្រើសយកជម្រើសដែលបន្ថយនីតិវិធី អង្គជំនុំជម្រះដើរតាមផ្លូវកាត់ជាច្រើន ដោយមិនគិតពីសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ៖ រំលោភគោលការណ៍ចំពោះមុខ អវត្តមាន ឬកង្វះខាតសំអាងហេតុនៃសេចក្តីសម្រេច...។ កំហុសមួយចំនួន (និងព្យសនកម្មដែលកើតមាន) ត្រូវបានលើកឡើងដោយអង្គជំនុំជម្រះតុលាការកំពូល[17]។ កំហុសខ្លះទៀតត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តីនានា ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់។

---

[12] សំណើសុំរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលអះអាងសាជាថ្មីអំពីសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយគោរពគោលការណ៍ចំពោះមុខ និងដោយយុត្តិធម៌ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E263។

[13] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124។

[14] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារ E163/5/1/1។

[15] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី។

[16] ការពន្យារពេលស្តាប់សក្ខីកម្មអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E264/3។

[17] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ១៧, ២៣, ២៤, ៣៣, ៣៥, ៣៦, កថាខណ្ឌ ៤០ ដល់កថាខណ្ឌ ៥០។

១៨. ក្នុងបរិបទនេះ **គឺលទ្ធភាពចេញសាលក្រមតែមួយគត់** ដែលទទួលរងនូវការប៉ះពាល់។ ជាក់ស្តែង ដោយសារតែភាពយឺតយ៉ាវ និងភាពស្មុគស្មាញនៃនីតិវិធីពន្លឿនល្បឿន តុលាការបានបាត់បង់ទំនុកចិត្តពីប្រទេសម្ចាស់ជំនួយ ហើយការលំបាកផ្នែកថវិការបស់តុលាការបានឈានដល់កម្រិតមិនធ្លាប់មានពីមុនមក ឧទាហរណ៍ អ្នកបកប្រែផ្ទាល់មាត់បានធ្វើកូដកម្មកាលពីពេលថ្មីៗនេះ ដែលធ្វើឱ្យការងារជាប់គាំង។

១៩. ដោយសារមូលហេតុទាំងអស់នេះ ស្ថានភាពបច្ចុប្បន្នបង្ហាញអំពី**ភាពមិនអាចព្យាករណ៍ទុកបាន និងគ្មានសច្ចភាពផ្លូវច្បាប់**។ ក៏ប៉ុន្តែ ការបំពេញតាមគោលការណ៍ទូទៅទាំងនេះមានសារៈសំខាន់ណាស់ នៅពេលការដកហូតសេរីភាពកំពុងចោទជាបញ្ហា[18]។

២០. ការបន្តឃុំខ្លួនជនជាប់ចោទ ដោយគ្មានលទ្ធភាពចេញសាលក្រម ក្នុងពេលអនាគតអាចព្យាករណ៍បាន និងមិននៅឆ្ងាយសន្លឹម ជារឿងមិនអាចទទួលយកបាន។ ក្រោយពីដកហូតសេរីភាពអស់រយៈពេលប្រាំឆ្នាំបួនខែ **ការបន្តឃុំខ្លួនលោក ខៀវ សំផន លែងជាហេតុផលសមស្រប ហើយក្លាយជាយូរហួសហេតុ**។

២១. អនុលោមតាមបទដ្ឋានអន្តរជាតិពាក់ព័ន្ធនឹងសិទ្ធិមនុស្ស រាល់ការដកហូតសេរីភាពត្រូវតែផ្អែកលើមូលហេតុសមស្រប ដែលកំណត់ដោយច្បាប់ ហើយចៅក្រមជាអ្នកធានាថា ការឃុំខ្លួនមិនពន្យារពេលហួសហេតុ ដោយរំលោភសិទ្ធិទាំងនេះ នោះទេ[19]។

---

[18] រឿងក្តី *Velichko ទល់នឹងប្រទេសរុស្ស៊ី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៣ ("រឿងក្តី *Velichko*") កថាខណ្ឌ ៦៧, រឿងក្តី *Tsitsiriggos ទល់នឹងប្រទេសក្រិច* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ៤៧-៤៨, រឿងក្តី *Tsarkov ទល់នឹងប្រទេសរុស្ស៊ី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ("រឿងក្តី *Tsarkov*") កថាខណ្ឌ ៤២ កថាខណ្ឌ ៥២-៥៤ (កថាខណ្ឌ ៥៣៖ *អ្នកស្នើសុំនៅតែមិនអាចប្រមើលមើលអំពីរយៈពេលនៃការបន្តឃុំខ្លួនគាត់*")។

[19] ឧទាហរណ៍ សូមមើល៖ *ព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga Dyilo* សាលដីកាលើបណ្តឹងសាទុក្ខរបស់ព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ១ មានចំណងជើងថា "សេចក្តីសម្រេចលើការដោះលែង Thomas Lubanga Dyilo ឱ្យនៅក្រៅឃុំ" ICC-01/04-01/06 OA 12 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៧។

២២. តុលាការសិទ្ធិមនុស្សអន្តរជាតិសន្និដ្ឋានជាឯកច្ឆន្ទថា ការឃុំខ្លួនបណ្ដោះអាសន្នយូរហួសហេតុប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ រួមទាំង នៅពេលបទល្មើសជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងស្មុគស្មាញបំផុត[20]។

២៣. សូម្បីតែនៅក្នុងរឿងក្ដីជាក់លាក់នេះ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបមានភាពពាក់ព័ន្ធ៖ នៅពេលចប់រយៈកាលណាមួយ មូលហេតុដែលបញ្ជាក់ការឃុំខ្លួនបណ្ដោះអាសន្នមិនគ្រប់គ្រាន់ទៀតឡើយ ហើយគ្រោះថ្នាក់ដែលបានលើកឡើងពីដំបូង ថយចុះជាចាំបាច់ ទៅតាមពេលវេលា[21]។

២៤. នៅក្នុងរឿងក្ដីប្រភេទនេះដដែល តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចកាលពីពេលថ្មីៗកន្លងទៅនេះថា រយៈពេលឃុំខ្លួនបណ្ដោះអាសន្នប្រហែលពីរ ឬបីឆ្នាំ យូរហួសហេតុ[22]។ តុលាការនេះក៏បានសង្កត់ធ្ងន់ផងដែរទៅលើករណីយកិច្ចរបស់ចៅក្រម ក្នុងការពិចារណាលើកាលៈទេសៈដោយឡែក

---

[20] សូមមើលយុត្តិសាស្ត្រដែលអង្គជំនុំជម្រះបានដកស្រង់ នៅកំណត់សម្គាល់ជើងទំព័រ ៥៦ នៃសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសមត្ថភាពខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារ E138/1/10។

[21] រឿងក្ដី *Letellier ទល់នឹង ប្រទេសបារាំង* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១ កថាខណ្ឌ ៣៥, ៣៩ និង ៥១, រឿងក្ដី *Labita ទល់នឹងប្រទេសអ៊ីតាលី* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៣, ១៥៩ និង ១៦៣, រឿងក្ដី *Soria Valderrama ទល់នឹងប្រទេសបារាំង* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ("រឿងក្ដី *Valderrama*") កថាខណ្ឌ ២៩-៣០, រឿងក្ដី *Pyatkov ទល់នឹងប្រទេសរុស្ស៊ី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("រឿងក្ដី *Pyatkov*") កថាខណ្ឌ ១០៧, ១១៥ និង ១១៨, រឿងក្ដី *Bilal Dogan ទល់នឹងប្រទេសទួរគី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("រឿងក្ដី *Dogan*") កថាខណ្ឌ ៣៩, រឿងក្ដី *Leontiuc ទល់នឹងប្រទេសរូម៉ានី* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ ("រឿងក្ដី *Leontiuc*") កថាខណ្ឌ ៧៦-៧៨, រឿងក្ដី *Velichko* កថាខណ្ឌ ៨៤, ៨៧, ៩០-៩២, រឿងក្ដី *Kowrygo ទល់នឹងប្រទេសប៉ូឡូញ* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("រឿងក្ដី *Kowrygo*") កថាខណ្ឌ ៦៣ កថាខណ្ឌ ៦៦-៦៧។

[22] រឿងក្ដី *Pyatkov*៖ ៣ ឆ្នាំ ៥ ខែ ៤ ថ្ងៃ, រឿងក្ដី *Dogan*៖ ៩ ខែ ២០ ថ្ងៃ, រឿងក្ដី *Leontiuc*៖ ២ ឆ្នាំ ១១ ខែ, រឿងក្ដី *Velichko*៖ ២ ឆ្នាំ ៤ ខែ, រឿងក្ដី *Kowrygo*៖ ១ ឆ្នាំ ៨ ខែ ២៥ ថ្ងៃ។ ក្នុងរឿងក្ដី *Valderrama* តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្នរយៈពេល ៤ ឆ្នាំ ៨ ខែ មិនសមហេតុផលទេ នៅពេលពិនិត្យជាបឋម (កថាខណ្ឌ ៣០)។ នៅក្នុងរឿងក្ដី *Tsarkov* តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ការឃុំខ្លួនបណ្ដោះអាសន្នលើសពី ៤ ឆ្នាំ *"ជាបញ្ហាព្រួយបារម្ភធ្ងន់ធ្ងរសម្រាប់តុលាការ"* (កថាខណ្ឌ ៦៤)។

ស្ថានភាពផ្ទាល់ខ្លួន និងអាកប្បកិរិយារបស់ជនសង្ស័យ ឬជនជាប់ចោទ[23]។

២៥. តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញយ៉ាងដូច្នេះថា *"ការមិនពិចារណាលើអាយុរបស់អ្នកស្នើសុំនៅពេលសម្រេចបន្តឃុំខ្លួនបណ្តោះអាសន្ន"* អាចជាល័ក្ខខ័ណ្ឌ *"គ្រប់គ្រាន់"* រួចទៅហើយ សម្រាប់ឲ្យតុលាការនេះសន្និដ្ឋានថារយៈពេលឃុំខ្លួនបណ្តោះអាសន្នយូរហួសហេតុ[24]។

២៦. នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ចៅក្រមក៏ពិចារណាផងដែរទៅលើស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ នៅពេលសម្រេចលើឱកាសក្នុងការអនុញ្ញាតឲ្យដោះលែងបណ្តោះអាសន្ន។ វ័យចាស់ជរារបស់ជនជាប់ចោទជាមូលដ្ឋានមួយសម្រាប់ឲ្យដោះលែង[25]។

២៧. លោក ខៀវ សំផន មានអាយុជិត ៨២ ឆ្នាំហើយ។ សព្វថ្ងៃនេះ គាត់ត្រូវបានដកហូតសេរីភាពអស់រយៈពេលប្រាំឆ្នាំបួនខែមកហើយ។ ឥឡូវនេះ គាត់មិនដឹងថាគាត់នឹងត្រូវវិនិច្ឆ័យទោសនៅពេលណា និងផ្អែកលើបែបបទអ្វីខ្លះនោះទេ។ អាស្រ័យហេតុនេះ ការបន្តឃុំខ្លួនបណ្តោះអាសន្នមិនត្រឹមតែជាការរំលោភលើសិទ្ធជាមូលដ្ឋានរបស់គាត់ប៉ុណ្ណោះទេ ថែមទាំងជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរជាមនុស្សទៀតផង។

## ២. <u>ហានិភ័យនៃការលាក់ខ្លួន ការគ្រាទើយគន្លើយចំពោះដីកាកោះ ឬបញ្ហារារាំងបណ្តោះ</u>

[23] រឿងក្តី *Velichko* កថាខណ្ឌ ៨៧, រឿងក្តី *Pyatkov* កថាខណ្ឌ ១១៤ និងកថាខណ្ឌ ១១៦, រឿងក្តី *Tsarkov* កថាខណ្ឌ ៦៧។

[24] រឿងក្តី *Dogan* កថាខណ្ឌ ៤២។ ជាការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន។ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា សមត្ថកិច្ចក្នុងការឃុំខ្លួនមនុស្សចាស់បណ្តោះអាសន្ន ចោទជាបញ្ហាក្នុងពេលបច្ចុប្បន្ននេះ យោងតាមមាត្រា ៣ នៃអនុសញ្ញាស្តីពីការធ្វើទារុណកម្ម និងការប្រព្រឹត្តិអមនុស្សធម៌ ឬបន្ថោកបន្ទាប៖ រឿងក្តី *Mouisel ទល់នឹងប្រទេសបារាំង* សាលដីកា តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០២ ("រឿងក្តី *Mouisel*") កថាខណ្ឌ ៣៨។

[25] ឧទាហរណ៍ សូមមើល៖ *ព្រះរាជអាជ្ញា ទល់នឹង Popovic និងអ្នកផ្សេងទៀត* IT-05-88-T សេចក្តីសម្រេចលើសំណើសុំដោះលែងបណ្តោះអាសន្នរបស់ជនជាប់ចោទ Radivoje Miletic និង Milan Gvero ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦ ទំព័រ ៧, *សេចក្តីសម្រេចលើសំណើសុំដោះលែងបណ្តោះអាសន្នរបស់ Gvero ពេលផ្អាកកិច្ចដំណើរការនីតិវិធី* ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៨ កថាខណ្ឌ ១៥-១៧។ នៅពេលនោះ Milan Gvero មានអាយុ ៧០ ឆ្នាំ។

## អាសន្ន

២៨. មុន និងចាប់តាំងពីពេលបង្កើតតុលាការ នៅឆ្នាំ ២០០៤ លោក ខៀវ សំផន មិនធ្លាប់ប៉ុនប៉ងលាក់ខ្លួនទាល់តែសោះ ទោះជាគាត់ដឹងថាគាត់ជា *"ជនមួយរូបប្រឈមនឹងការកាត់ទោស"*[26] ក៏ដោយ។ គាត់មិនបានរើផ្ទះនោះទេ ហើយថែមទាំងបានឆ្លើយតបទៅនឹងកិច្ចសម្ភាសន៍ជាច្រើន រហូតដល់មុនពេលចាប់ខ្លួន ដែលក្នុងពេលនោះ គាត់បានប្រគល់ខ្លួនដោយស្ម័គ្រចិត្ត។ ដូច្នេះ លោក ខៀវ សំផន មិនធ្លាប់គេចវេះពីតុលាការទាល់តែសោះ។ ផ្ទុយទៅវិញ គាត់បានសម្តែងឆន្ទៈជាសាធារណៈថានឹងបង្ហាញខ្លួននៅតុលាការ និងការពារខ្លួនចំពោះការចោទប្រកាន់នានាមកលើរូបគាត់[27]។

២៩. ម្យ៉ាងវិញទៀត លោក ខៀវ សំផន គ្មានលិខិតឆ្លងដែន គ្មានប្រាក់ គ្មានលំនៅដ្ឋាននៅបរទេស ហើយគាត់ជិតដិតនឹងគ្រួសារណាស់ (គ្រួសារតែងតែមកសួរសុខទុក្ខគាត់ជាទៀងទាត់ នៅមន្ទីរឃុំឃាំង)។ លើសពីនេះទៅទៀត ការគិតថា ខៀវ សំផន អាចវិលត្រឡប់ទៅរស់នៅក្នុងព្រៃវិញនៅអាយុជិត ៨២ ទៅហើយនោះ ជារឿងមិនទំនងទាល់តែសោះ។

៣០. ជាចុងក្រោយ លោក ខៀវ សំផន នឹងអាចមាន *"បញ្ហារាំងបណ្តោះអាសន្ន"* ដោយសារតែមូលហេតុសុខភាពប៉ុណ្ណោះ។ ក៏ប៉ុន្តែ ហានិភ័យនេះអាចកើតមាននៅគ្រប់ទីកន្លែង ទោះជានៅពេលឃុំខ្លួន ឬដោះលែងក៏ដោយ។ ដូច្នេះ ហានិភ័យនេះមិនអាចធ្វើជាសំអាងផ្លូវច្បាប់ សម្រាប់ដកហូតសេរីភាពរបស់គាត់នោះទេ។ ផ្ទុយទៅវិញ យើងថែមទាំងអាចនិយាយបានថា ហានិភ័យនេះកើនឡើងខ្ពស់ នៅក្នុងមន្ទីរឃុំឃាំង ដោយសារតែការឃុំខ្លួនរឹតតែធ្វើឲ្យគាត់ឈឺទៅវិញទេ។

## ខ. ហានិភ័យចំពោះសណ្តាប់ធ្នាប់សាធារណៈ:

[26] *Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge* និពន្ធដោយ Stephen Heder និង Brian Tittemore ខែ មីនា ឆ្នាំ ២០០៤ ឯកសារ E3/48 ទំព័រ ៩២-៩៩។

[27] ឧទាហរណ៍ សូមមើល៖ បទសម្ភាសន៍របស់វិទ្យុសម្លេងសហរដ្ឋអាមេរិក ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ E3/588 និង E3/588.1។

៣១. នៅឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលហានិភ័យនៃការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ[28]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គហេតុជាក់ស្តែង ក្នុងអំឡុងដំណាក់កាលស៊ើបសួរ បានបង្ហាញថាប្រសិនបើលោក ខៀវ សំផន ត្រូវបានដោះលែង វត្តមានគាត់ក្នុងការជំនុំជម្រះក្តីអាចត្រូវបានប៉ះពាល់ ដោយសារតែរំខានដល់សណ្តាប់ធ្នាប់សាធារណៈ[29]។

៣២. អង្គហេតុ *"ជាក់ស្តែង"* ពីមុន គឺជាតម្រុយ ផ្អែកលើសេចក្តីថ្លែងការណ៍ និងប្រតិកម្មមួយចំនួនរបស់ជនរងគ្រោះ (នៅឆ្នាំ ២០០៨) ផ្អែកលើការស្ទង់មតិ (ឆ្នាំ ២០០៨ និងឆ្នាំ ២០១០) ផ្អែកលើការវាយតម្លៃថាប្រជាជនកម្ពុជាមួយភាគ ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ កើតជំងឺបាក់ស្បាត ផ្អែកលើបរិបទងាយប្រេះឆានៃសង្គមកម្ពុជា និងការចាប់អារម្មណ៍ *"យ៉ាងខ្លាំង"* ពីមតិសាធារណៈទៅលើរឿងក្តីនេះ[30]។

៣៣. តម្រុយទាំងនេះត្រូវបាន *"បង្កើតឡើង"* តាមរយៈសេចក្តីសម្រេចមុនៗ ដែលបានចេញក្នុងដំណាក់កាលស៊ើបសួរ សម្រាប់ជាមូលដ្ឋាននៃការបន្តឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ ជាសហជនជាប់ចោទរបស់លោក ខៀវ សំផន។ ក៏ប៉ុន្តែ ការព្យាករណ៍ប្រកបដោយទុទ្ទិដ្ឋិនិយមដែលត្រូវបានប្រើប្រាស់នៅពេលនោះ គឺខុស។ ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ចាប់តាំងពីថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២ ជាថ្ងៃដោះលែងលោកស្រី អៀង ធីរិទ្ធ *"ពុំមានភស្តុតាងបង្ហាញថា*

---

[28] សម្រាប់ជនជាប់ចោទនីមួយៗក្នុងចំណោមជនជាប់ចោទទាំង ៣ នាក់៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១ កថាខណ្ឌ ៣៩-៤១។

[29] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥៤។

[30] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ C26/5/26 ("សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩") កថាខណ្ឌ ៦៣, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ឯកសារ C26/9/12 ("សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០១០") កថាខណ្ឌ ៣៨-៣៩, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឲ្យដោះលែងជាបន្ទាន់ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ឯកសារ E50/3/1/1 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន") កថាខណ្ឌ ២៧-២៨។

*មានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ”*[31]។

៣៤. លើសពីនេះទៀត ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់បានមកផ្តល់សក្ខីកម្មនៅតុលាការ តាំងពីចុង ឆ្នាំ ២០១១។ ទោះបីជា ពេលខ្លះ ពួកគាត់មានអារម្មណ៍រំជួលចិត្ត ក៏គ្មានអ្នកណាម្នាក់បង្ហាញឲ្យឃើញនូវសញ្ញានៃការសងសឹកនោះឡើយ[32]។

៣៥. ជាចុងក្រោយ ឆ្លងតាមការសិក្សាដែលសហព្រះរាជអាជ្ញាមិនលើកឡើង ប្រជាជនកម្ពុជាមិនចាប់អារម្មណ៍ទាល់តែសោះទៅនឹងរឿងក្តីកំពុងជំនុំជម្រះនេះ។ យ៉ាងណាមិញ នៅឆ្នាំ ២០០៨ ប្រជាជនកម្ពុជាតែ ៣% ប៉ុណ្ណោះមានលទ្ធភាពអាចប្រាប់ឈ្មោះជនជាប់ចោទ នៅចំពោះមុខ អ.វ.ត.ក។ នៅឆ្នាំ ២០១០ ក្រោយពីកម្មវិធីអប់រំផ្សព្វផ្សាយអំពីការងាររបស់តុលាការ មានតែ ១១% ប៉ុណ្ណោះអាចប្រាប់ឈ្មោះជនជាប់ចោទបាន។ នៅឆ្នាំ ២០១០ ប្រជាជនកម្ពុជា ៨៣% យល់ឃើញថាគួរតែផ្តោតលើបញ្ហាបច្ចុប្បន្នរបស់កម្ពុជា ទល់នឹង ១៦% ដែលយល់ឃើញថាគួរផ្តោតលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[33]។

## គ. **<u>ហានិភ័យចំពោះសុវត្ថិភាពរបស់លោក ខៀវ សំផន</u>**

---

[31] *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខ័ណ្ឌ* អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារ E138/1/10/1/5/7 (“សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២”) កថាខណ្ឌ ៦៥ កំណត់សម្គាល់ជើងទំព័រ ២០៨។

[32] សូមមើល ប្រតិចារឹកសវនាការ ឯកសារ E1/17.1, E1/18.1, E1/24.1, E1/25.1, E1/113.1, E1/115.1, E1/116.1, E1/117.1, E1/135.1, E1/136.1, E1/137.1, E1/138.1, E1/141.1, E1/144.1, E1/145.1, E1/146.1, E1/147.1, E1/148.1, E1/149.1, E1/152.1, E1/153.1, E1/170.1។

[33] *After the first trial* មជ្ឈមណ្ឌលសិទ្ធិមនុស្ស សាកលវិទ្យាល័យ Berkeley រដ្ឋកាលីហ្វ័រញ៉ា ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ២០ និង ២៣។

៣៦. នៅឆ្នាំ ២០១១ អង្គជំនុំជម្រះបានច្រានចោលហានិភ័យប៉ះពាល់ដល់សុវត្ថិភាពលោក ខៀវ សំផន[34]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គហេតុទាំងនេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចមុនៗថា ប្រសិនបើជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាព វត្តមានរបស់គាត់ក្នុងការជំនុំជម្រះក្តីអាចត្រូវបានប៉ះពាល់ ដោយសារតែការវាយប្រហារលើរូបគាត់[35]។

៣៧. អង្គហេតុ *"ជាក់ស្តែង"* ពីមុន និងត្រូវបានប្រើប្រាស់ដោយអង្គជនុំជម្រះតុលាការកំពូល ត្រូវបានលើកឡើងនៅក្នុងសេចក្តីសម្រេចមុនពីររបស់អង្គបុរេជំនុំជម្រះ។ អង្គហេតុទាំងនេះមានដូចជា៖ ការបំពារបំពានលើរូបលោក ខៀវ សំផន ក្នុងឆ្នាំ ១៩៩១ ការគំរាមកំហែងមួយចំនួន (ក្នុងឆ្នាំ ២០០៨ និងឆ្នាំ ២០០៩) ចំពោះមេដឹកនាំខ្មែរក្រហម និយាយជារួម ចំពោះលោក នួន ជា និងលោក កាំង ហ្គេកអ៊ាវ ហៅឌុច និយាយដោយឡែក និងការលម្មៀងរបស់អតីតមេធាវីកម្ពុជាការពារក្តីលោក ខៀវ សំផន ក្នុងអំឡុងសន្និសីទសារព័ត៌មាននៅ អ.វ.ត.ក ក្នុងឆ្នាំ២០០៨[36]។

៣៨. នៅពេលនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា *"ប្រតិកម្មរំជួលចិត្ត ដូចបានប៉ាន់ស្មានដោយអ្នកជំនាញផ្នែកវិកលវិទ្យា បង្ហាញថា កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក អាចបណ្តាលឱ្យជនរងគ្រោះដែលកើតជំងឺបាក់ស្បាត លេចឡើងជាថ្មីនូវភាពតានតឹងក្នុងអារម្មណ៍ និងនាំឱ្យកើនឡើងនូវផលវិបាកសង្គមជាអវិជ្ជមាន ដែលអាចមានចំពោះពួកគាត់"*[37]។ ក្រៅពីនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថា *"ដូចដែលសហព្រះរាជអាជ្ញាបានអះអាង ដំណាក់កាលនីតិវិធីចុងក្រោយនៃសំណុំរឿង ០០១ និងការចេញសាលក្រមនាពេលខាងមុខ បង្កើតជាឱកាសសមស្របសម្រាប់ប្រតិកម្មខ្លាំងក្លាបន្ថែមទៅលើជនត្រូវចោទ"*[38]។

---

[34] សម្រាប់ជនជាប់ចោទនីមួយៗក្នុងចំណោមជនជាប់ចោទទាំង ៣ នាក់៖ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឆ្នាំ ២០១១ កថាខណ្ឌ ៣៩-៤១។

[35] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥៤។

[36] សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ កថាខណ្ឌ ៥៣-៥៨, សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០១០ កថាខណ្ឌ ៣៤-៣៥, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន កថាខណ្ឌ ២៤-២៦។

[37] សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ កថាខណ្ឌ ៥៧។

[38] សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០១០ កថាខណ្ឌ ៣៤។

៣៩. *"ឱកាសសមស្រប"* នេះលែងមានទៀតហើយ ពីព្រោះថា នៅខែ កុម្ភៈ ឆ្នាំ ២០១២ ឌុច ត្រូវបាន ផ្តន្ទាទោសជាស្ថាពរឱ្យជាប់ពន្ធនាគារអស់មួយជីវិត[39] ហើយការផ្តន្ទាទោសនេះត្រូវសម្រាលជា ដាច់ខាតនូវ *"ភាពតានតឹងក្នុងអារម្មណ៍របស់ជនរងគ្រោះដែលកើតជំងឺបាក់ស្បាត* និងកាត់បន្ថយ *"ការនាំឱ្យកើនឡើងនូវផលវិបាកសង្គមជាអវិជ្ជមាន ដែលអាចមានចំពោះពួកគាត់"*។

៤០. ចំពោះការបំពារបំពានលើរូបលោក ខៀវ សំផន នៅឆ្នាំ ១៩៩១ នេះជារឿងតាំងពីយូរយារណាស់ មកហើយ ជាពិសេស អ្នកអត្ថាធិប្បាយជាច្រើនអំពីហេតុការណ៍នេះឯកភាពថា នេះជាការរៀបចំ របស់រដ្ឋាភិបាលកាន់អំណាច។ម្យ៉ាងវិញទៀត ដូចបានបញ្ជាក់រួចមកហើយ លោក ខៀវ សំផន មិនធ្លាប់ទទួលរងនូវការជេរប្រមាថ ឬគំរាមកំហែង ពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ដែលមកផ្តល់សក្ខីកម្មនៅតុលាការនេះឡើយ[40]។

៤១. ចំពោះឧប្បត្តិហេតុពាក់ព័ន្ធនឹងមេធាវីកម្ពុជាការពារក្តីរបស់គាត់ គួរកត់សម្គាល់ថា នេះគ្រាន់តែជា សម្តីជាក់លាក់សំដៅលើមេធាវី (មិនមែនសំដៅលើសាមីខ្លួនទេ) ហើយជាពិសេស ចាប់តាំងពីមាន ឧប្បត្តិហេតុនោះមក លោក ខៀវ សំផន បានផ្លាស់ប្តូរមេធាវីជាតិរបស់គាត់ចេញហើយ។

៤២. ជាចុងក្រោយ ចំពោះលោក ខៀវ សំផន ដែលត្រូវបានដាក់បញ្ចូលក្នុងការគំរាមកំហែងលើអតីត មេដឹកនាំខ្មែរក្រហម គ្មានអ្វីត្រូវខ្លាចចំពោះសុវត្ថិភាពរបស់គាត់ ជាងសុវត្ថិភាពរបស់ អៀង ធីរិទ្ធ នោះទេ។ ក៏ប៉ុន្តែ ចាប់តាំងពី អៀង ធីរិទ្ធ ត្រូវបានដោះលែងមក *"ពុំមានភ័ស្តុតាងបង្ហាញថាមាន ការរំខានដល់សណ្តាប់ធ្នាប់សាធារណៈនោះឡើយ"*[41]។

## ឃ. **ហានិភ័យនៃកង្វះការថែទាំវេជ្ជសាស្ត្រសមស្រប នៅពេលលោក ខៀវ សំផន ត្រូវការ**

៤៣. ហានិភ័យនេះ ដែលលើកឡើងថ្មីៗនេះដោយអង្គជំនុំជម្រះតុលាការកំពូល ផ្អែកតែលើការពិចារណា

[39] រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28។

[40] សូមមើលខាងលើ កថាខណ្ឌ ៣៤ កំណត់សម្គាល់ជើងទំព័រ ៣២។

[41] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កថាខណ្ឌ ៦៥ កំណត់សម្គាល់ជើងទំព័រ ២០៨។

ជាក់ស្តែង និងមិនមានមូលដ្ឋាននោះទេ។ ជាក់ស្តែង លោកខៀវ សំផន មិនមានជំងឺរ៉ាំរ៉ៃនោះទេ។ ការថែទាំវេជ្ជសាស្ត្រអាចត្រូវបានផ្តល់ជូនគាត់ នៅពេលគាត់ទៅចូលរួមសវនាការ និងនៅក្រៅតុលាការ ទៅតាមតម្រូវការ។

៤៤. ដូច្នេះ ទោះជាក្នុងករណីណាក៏ដោយការពិចារណាជាក់ស្តែងនេះមិនអាចជាមូលដ្ឋានផ្លូវច្បាប់ក្នុងការដកហូតសេរីភាពរបស់លោក ខៀវ សំផន ដែលត្រូវសន្មតថាមានសុខភាពល្អ និងជាពិសេសត្រូវបានសន្មតថាគ្មានទោស នោះទេ។

៤៥. ជាចុងក្រោយ ហានិភ័យដែលបានលើកឡើងសម្រាប់ជាហេតុផលក្នុងការបន្តឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន មានតិចតួចបំផុត ពោលគឺ គ្មានតែម្តង។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងត្រូវ *"វាយតម្លៃថា តើហានិភ័យទាំងនេះនឹងអាចកាត់បន្ថយបានក្នុងកម្រិតណាតាមរយៈវិធានការក្រៅពីការបន្តឃុំខ្លួនជនជាប់ចោទ"*[42]។

## II- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគ្រប់គ្រាន់នឹងបង្ការរាល់ហានិភ័យ

៤៦. យោងតាមសច្ចធារណ៍និរទោស និងគោលការណ៍ជាមូលដ្ឋានថា សេរីភាពជាវិធានទូទៅ ហើយការឃុំខ្លួនជាករណីលើកលែង អង្គជំនុំជម្រះអាចបង្គាប់ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅគ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី[43]។

៤៧. ដូចអង្គបុរេជំនុំជម្រះបានរំឭក មានការទទួលស្គាល់ជាទូទៅថា៖ *"វិធានការនៅក្នុងច្បាប់អន្តរជាតិសាធារណៈ មានសមាមាត្រ តែក្នុងករណីវិធានការនោះ (១) សមស្រប (២) ចាំបាច់ (៣) កម្រិតនិងវិសាលភាពរបស់វានៅតែមានភាពសមហេតុផល ធៀបនឹងគោលបំណងដែលបានគ្រោងទុក។ វិធានការនីតិវិធីមិនគួរធ្វើឡើងតាមទំនើងចិត្ត ឬហួសហេតុពេកនោះទេ។ ប្រសិនបើមានវិធានការ*

[42] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី ខៀវ សំផន កថាខណ្ឌ ៥៤។

[43] វិធាន ៦៣, ៦៥ និង ៨២ នៃវិធានផ្ទៃក្នុង, ជំពូក ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, សូមមើលផងដែរ សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ កថាខណ្ឌ ៩០ ដែលរំឭកអំពីគោលការណ៍សច្ចធារណ៍និរទោស និងឧត្តមភាពនៃសេរីភាព, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កថាខណ្ឌ ៥៥ អំពីភាពគ្មានវិមតិសង្ស័យចំពោះលទ្ធភាពដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ នៅក្នុងដំណាក់កាលជំនុំជម្រះក្តី។

*ស្រាលជាង ត្រូវអនុវត្តវិធានការនោះ”*[44]។

៤៨. អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងនូវគោលការណ៍ទាំងនេះ ហើយបានបញ្ជាក់ថា៖ *“សេចក្ដីសម្រេចដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ផ្អែកលើអង្គហេតុទាំងស្រុង និងត្រូវពិចារណាទៅតាមលក្ខណៈជាក់ស្ដែងរបស់បុគ្គលម្នាក់ៗ។ (...) របបនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចមាននៅចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៦៥ នៃវិធានផ្ទៃក្នុង មានលក្ខណៈបត់បែនគ្រប់គ្រាន់ក្នុងការអនុញ្ញាតឱ្យមានតុល្យភាពរវាងផលប្រយោជន៍ផ្សេងៗ និងបង្កើតរបបមួយសមស្របក្នុងកាលៈទេសៈនោះ”*[45]។

៤៩. ក្នុងករណីនេះ ការបន្តឃុំខ្លួនលោក ខៀវ សំផន ជាការមិនសមស្រប មិនចាំបាច់ និងហួសហេតុ។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាការគ្រប់គ្រាន់ សម្រាប់ឱ្យសម្រេចគោលបំណងដូចគ្នានេះ។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អមដោយការធានាផ្សេងៗ និងតាមរយៈវិធានការជូនដំណឹងដល់សាធារណជន។

## គ. <u>ដំណោះស្រាយជាក់ស្ដែងអាចធ្វើទៅបាន ជំនួសឱ្យការឃុំខ្លួន</u>

៥០. មេធាវីការពារក្ដីលោក ខៀវ សំផន សូមស្នើឡើងនូវបញ្ជីវិធានការខ្លះៗ ដែលយើងខ្ញុំយល់ឃើញថាសមស្រប និងមានសមាមាត្រ។ កាតព្វកិច្ចទាំងនេះបង្ការហានិភ័យដែលបានលើកឡើងពីខាងលើ។

### ១. <u>កាតព្វកិច្ចក្នុងការស្នាក់នៅអាសយដ្ឋានជាក់លាក់ណាមួយ និងកាតព្វកិច្ចក្នុងការមិនផ្លាស់ប្ដូរអាសយដ្ឋាន ដោយគ្មានការអនុញ្ញាត</u>

៥១. អាសយដ្ឋានដែលលោក ខៀវ សំផន អាចនឹងស្នាក់នៅ ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃសំណើសុំ

---

[44] សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ កថាខណ្ឌ ៩១។

[45] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កថាខណ្ឌ ៥៨។

ដោះលែងឲ្យនៅក្រៅឃុំ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ យើងខ្ញុំសូមបញ្ជាក់ថា លោក ខៀវ សំផន នឹងមិនរស់នៅតែម្នាក់ឯងនៅអាសយដ្ឋាននេះទេ ហើយក្រុមគ្រួសារគាត់នឹងមកសួរសុខទុក្ខជាប្រចាំ។

## ២. ភាតព្វកិច្ចក្នុងការប្រគល់អត្តសញ្ញាណប័ណ្ណជូនការិយាល័យក្រឡាបញ្ជី

៥២. បើគ្មានអត្តសញ្ញាណប័ណ្ណ លោក ខៀវ សំផន នឹងមិនអាចធ្វើលិខិតឆ្លងដែនបាននោះទេ ហើយគាត់ក៏មិនអាចឆ្លងព្រំដែនបានដែរ។

## ៣. ភាតព្វកិច្ចក្នុងការអនុញ្ញាតឲ្យអាជ្ញាធរត្រួតពិនិត្យជាទៀងទាត់

៥៣. ឧទាហរណ៍ លោក ខៀវ សំផន អាចនឹងអនុញ្ញាតឲ្យអាជ្ញាធរត្រួតពិនិត្យម្តង ឬច្រើនដងក្នុងមួយខែក្នុងពេលមានសវនាការ និងច្រើនដងក្នុងមួយសប្តាហ៍ ក្នុងពេលផ្អាកសវនាការ។ របាយការណ៍ធ្វើឡើងដោយអាជ្ញាធរនឹងអនុញ្ញាតឲ្យតុលាការកត់សម្គាល់ឃើញថា លោក ខៀវ សំផន បន្តស្នាក់នៅអាសយដ្ឋានខាងលើ និងគោរពតាមកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀត ការត្រួតពិនិត្យជាទៀងទាត់ពីសំណាក់អាជ្ញាធរ នឹងអនុញ្ញាតឲ្យបង្ការហានិភ័យនៃការប៉ះពាល់ដល់សុវត្ថិភាពរបស់លោក ខៀវ សំផន ខណៈដែលរាជរដ្ឋាភិបាលកម្ពុជាជាអ្នកធានាសុវត្ថិភាព[46]។

## ៤. ភាតព្វកិច្ចក្នុងការពិភាក្សាអំពីរឿងក្តីតែជាមួយមេធាវី និងភាតព្វកិច្ចក្នុងការមិនទំនាក់ទំនងជាមួយសារព័ត៌មាន

៥៤. វិធានការនេះនឹងអនុញ្ញាតឲ្យបង្ការហានិភ័យនៃការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ និងជៀត

---

[46] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២00៣ A/RES/57/228 B ("កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា") មាត្រា ២៤។

ជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ។

## ៥. កាតព្វកិច្ចក្នុងការមិនទាក់ទងជាមួយសាក្សី អ្នកជំនាញ ឬដើមបណ្ដឹងរដ្ឋប្បវេណី

៥៥. ឥឡូវនេះ យើងមិនអាចដឹងថា តើសាក្សីដែលបានផ្ដល់សក្ខីកម្មរួចហើយ នឹងត្រូវកោះហៅម្ដងទៀត ឬក៏យ៉ាងណានោះទេ។ លើសពីនេះទៅទៀត ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញសេចក្ដីសម្រេចមានសំអាងហេតុគ្រប់គ្រាន់ចំពោះសាក្សីទាំងអស់ដែលភាគីបានស្នើ យើងមិនអាចដឹងថា តើសាក្សីណាខ្លះដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងកោះហៅ ក្នុងក្របខ័ណ្ឌនៃការជំនុំជម្រះក្ដីវគ្គមួយ និងវគ្គបន្តបន្ទាប់ នោះទេ។ ដូច្នេះ កាតព្វកិច្ចនេះនឹងត្រូវលាតសន្ធឹងដល់រាល់បុគ្គលទាំងឡាយដែលភាគីបានស្នើឲ្យកោះហៅ។ ទោះជាយ៉ាងណា កាតព្វកិច្ចនេះមិនអនុវត្តចំពោះសាក្សី TCW-673 នោះទេ។

៥៦. កាតព្វកិច្ចនេះនឹងបង្ការរាល់ហានិភ័យនៃការគៀបសង្កត់សាក្សី និងបំផ្លាញភស្តុតាង[47] ទោះបីជាហានិភ័យនេះមិនមែនជាមូលដ្ឋានសម្រាប់បន្តឃុំខ្លួនលោក ខៀវ សំផន[48] ក៏ដោយ ហើយកាតព្វកិច្ចនេះជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូបក្នុងការមិនជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ[49]។

## ៦. កាតព្វកិច្ចក្នុងការទទួលបានការពិនិត្យសុខភាពជាទៀងទាត់

៥៧. លោក ខៀវ សំផន នឹងត្រូវទទួលបានការពិនិត្យសុខភាពជាទៀងទាត់ ដោយគ្រូពេទ្យដែលចាត់តាំងពីអង្គជំនុំជម្រះសាលាដំបូង ឧទាហរណ៍ ម្ដងក្នុងមួយខែ ក្នុងពេលមានសវនាការ និងម្ដងក្នុង

---

[47] វិធាន ៦៣(៣) (ខ) i) និង ii) នៃវិធានផ្ទៃក្នុង។

[48] ហានិភ័យនេះត្រូវបានច្រានចោលយ៉ាងច្បាស់ នៅឆ្នាំ ២០០៩៖ សាលដីការបស់អង្គបុរេជំនុំជម្រះ ឆ្នាំ ២០០៩ កថាខណ្ឌ ៤៨-៤៩។

[49] វិធាន ៣៥ នៃវិធានផ្ទៃក្នុង, សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កថាខណ្ឌ ៧៨។

មួយសប្តាហ៍ ក្នុងពេលផ្អាកសវនាការ។ វិធានការនេះ[50] នឹងអាចបង្ការហានិភ័យដូចអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើង ពាក់ព័ន្ធនឹងកង្វះការថែទាំវេជ្ជសាស្ត្រ នៅពេលលោកខៀវ សំផន ត្រូវការ និងកាត់បន្ថយហានិភ័យដែលថាគាត់អាចមានបញ្ហារារាំងបណ្តោះអាសន្ន។

## ៧. កាតព្វកិច្ចក្នុងការអនុញ្ញាតឲ្យមន្ត្រី អ.វ.ត.ក (ឬអាជ្ញាធរ) ដឹកនាំទៅតុលាការ

៥៨. កាតព្វកិច្ចនេះនឹងអាចឲ្យអង្គជំនុំជម្រះសាលាដំបូងធានាថា លោក ខៀវ សំផន នឹងមានវត្តមានក្នុងសវនាការ និងបង្ការរាល់ហានិភ័យនៃការប៉ះពាល់ដល់សុវត្ថិភាពគាត់ ក្នុងពេលកំពុងធ្វើដំណើរ។

## ខ. ការធានាវត្តមាន និងគ្មានការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ

៥៩. លោក ខៀវ សំផន បានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរថានឹងមានវត្តមាននៅសវនាការ ហើយកិច្ចសន្យានេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ។ នៅក្នុងលិខិតនោះ គាត់សន្យាថានឹងមានវត្តមាននៅពេលជំនុំជម្រះក្តី និងគោរពរាល់កាតព្វកិច្ចទាំងឡាយ ដែលកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។ គាត់ក៏សន្យាផងដែរថានឹងមិនជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ និងមិនបង្កគ្រោះថ្នាក់អ្វីដល់តតិយជនឡើយ។

៦០. លើសពីនេះទៀត សូមរំឭកថា សុទ្ធចិត្តរបស់លោក ខៀវ សំផន និងឆន្ទៈរបស់គាត់ក្នុងការចូលរួមជំនុំជម្រះក្តី មិនអាចសង្ស័យបានឡើយ។ ជាក់ស្តែង គាត់មិនធ្លាប់ប៉ុនប៉ងគេចវេះពីតុលាការនោះទេ ផ្ទុយទៅវិញ គាត់តែងតែបានបង្ហាញនូវឆន្ទៈក្នុងការការពារខ្លួនពីការចោទប្រកាន់មកលើរូបគាត់[51]។ ម្យ៉ាងវិញទៀត គាត់មានកេរ្តិ៍ឈ្មោះល្អ ហើយសុចរិតភាពរបស់គាត់ក៏ត្រូវបានលើកឡើងនៅក្នុងសវនាការ ជាពិសេស ដោយអ្នកជំនាញខាងប្រវត្តិសាស្ត្រ[52]។ ក្រៅពីនេះ គាត់បានបង្ហាញនូវ

---

[50] ចែងយ៉ាងច្បាស់នៅក្នុងមាត្រា ២២៣(១១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[51] សូមមើលខាងលើ កថាខណ្ឌ ២៨។

[52] ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/93.1 ទំព័រ ៧៨ បន្ទាត់ ២០-២៤, ប្រតិចារឹកសវនាការ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ E1/95.1 ទំព័រ ៧១-៧២។

អាកប្បកិរិយាគំរូ តាំងពីពេលចាប់ផ្តើមការជំនុំជម្រះក្តីមក ហើយអ្នកណាក៏ដឹងដែរថា លោក ខៀវ សំផន យកចិត្តទុកដាក់ស្តាប់សវនាការ ហើយគាត់ខិតខំចូលរួម ទាំងពេលព្រឹក និងពេលរសៀល។

៦១. ការធានាវត្តមានលោក ខៀវ សំផន មួយទៀត ត្រូវបានផ្តល់ដោយការសន្យារបស់បុគ្គលដែលគាត់នឹងទៅរស់នៅជាមួយ (ភ្ជាប់ជាឧបសម្ព័ន្ធ)។ អ្នកទាំងនេះមិនធ្លាប់មានបញ្ហាពាក់ព័ន្ធនឹងតុលាការទេ ហើយរស់នៅយ៉ាងចុះសម្រុងក្នុងសង្គមកម្ពុជា។

៦២. លើសពីនេះទៀត មេធាវីការពារក្តីសូមរំឭកថាអង្គជំនុំជម្រះសាលាដំបូងអាចជឿជាក់លើនគរបាលយុត្តិធម៌នៃ អ.វ.ត.ក និងកិច្ចសហប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជា[53]។

## គ. វិធានការអមនឹងការដោះលែងឲ្យនៅក្រៅឃុំ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖ ការជូនដំណឹងដល់សាធារណជន

៦៣. នៅពេលលោកស្រី អៀង ធីរិទ្ធ ត្រូវបានដោះលែង មានការចាត់វិធានការមួយចំនួន ដើម្បីជូនដំណឹងដល់សាធារណជនអំពីមូលហេតុនៃការសម្រេចដោះលែង។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា សេចក្តីសម្រេចនេះត្រូវបានយល់ជ្រួតជ្រាបជាទូទៅ និងទទួលបាន ក្នុងចំណោមប្រជាជន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា *"ការជូនដំណឹងដល់សាធារណជន គឺជាមធ្យោបាយល្អបំផុតក្នុងកាលៈទេសៈនេះ ដើម្បីធានានូវការការពារសណ្តាប់ធ្នាប់សាធារណៈ"*[54]។ មេធាវីការពារក្តីសូមស្នើថា វិធានការស្រដៀងគ្នាក្នុងការជូនដំណឹងដល់សាធារណជនត្រូវអនុវត្តនៅពេលដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំ ដោយដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

---

[53] វិធាន ១៥ នៃវិធានផ្ទៃក្នុង, មាត្រា ២៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ សូមមើលផងដែរ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កថាខណ្ឌ ៧៣ កំណត់សម្គាល់ជើងទំព័រ ២២៥ និង ២២៦។

[54] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្តីពី អៀង ធីរិទ្ធ ឆ្នាំ ២០១២ កំណត់សម្គាល់ជើងទំព័រ ២០៨។

៦៤. ជាសេចក្តីសន្និដ្ឋាន រយៈពេលឃុំខ្លួនបណ្តោះអាសន្នលោក ខៀវ សំផន យូរហួសហេតុពេក និងនាំឲ្យរំលោភសិទ្ធិជាមូលដ្ឋានរបស់គាត់។ ហានិភ័យដែលត្រូវបានប្រើប្រាស់តាំងពីដំបូង សម្រាប់ជាហេតុផលក្នុងការដកហូតសេរីភាពលោក ខៀវ សំផន មានតិចតួចបំផុត ពោលគឺគ្មានតែម្តង។ ហានិភ័យនីមួយៗអាចត្រូវបានបង្ការ តាមរយៈការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការបើកសវនាការជាសាធារណៈមានភាពចាំបាច់ មិនត្រឹមតែដើម្បីអនុញ្ញាតឲ្យមេធាវីការពារក្តីលើកឡើងនូវទឡ្ហីករណ៍ប៉ុណ្ណោះទេ ថែមទាំងអាចឲ្យលោក ខៀវ សំផន ធានាអះអាងជូនអង្គជំនុំជម្រះសាលាដំបូង និងសាធារណជន ថាគាត់នឹងគោរពកាតព្វកិច្ចដែលនឹងដាក់ចំពោះគាត់ ហើយគាត់នឹងមានវត្តមាន ក្នុងពេលជំនុំជម្រះក្តី។

៦៥. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **សម្រេច និងប្រកាសថា** សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានការជំនុំជម្រះក្តីក្នុងរយៈពេលសមស្រប ត្រូវបានរំលោភបំពាន
- **សម្រេច និងប្រកាសថា** ការបន្តឃុំខ្លួនលោក ខៀវ សំផន ជាការហួសហេតុ និងលែងមានមូលដ្ឋាន
- **បង្គាប់** ឲ្យដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់
- **បង្គាប់** ឲ្យចាត់វិធានការត្រួតពិនិត្យតាមផ្លូវតុលាការ ភ្ជាប់ជាមួយនឹងការដោះលែងនេះ
- **កំណត់** ពេលបើកសវនាការជាសាធារណៈ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |